រឿងអប់រំខ្លី ស្តីពីសុវត្ថិភាពលើកម្មវិធី **Tor**

# ឈុតខ្លីនាំរឿង




រកឈុតក្នុង
ឲ្យប្រពន្ធ១សិន
អាហ៎ា !!!
ដល់ម៉ោង
បាយល្ងាច !
ប៊ុប៊ ប៊ុប៊


ទីង ទីង
Email.
ផ្ទាំងពាណិជ្ជកម្ម
ប៉ុប ប៉ុប
ប៉ុប ប៉ុប
Email.
ប៉ុប ប៉ុប


ផាំង
ផាំង
ប្អូន! កំពុងធ្វើអីហ្នឹង?
ធ្វើការបង!
ធ្វើការម៉េចចេញគ្រឿងក្នុងអាចឹង?


បងមានរឿងថ្មីមួយទើបចេញ ល្អមើលណាស់ !
រឿងអីគេ បូ៉ា?
នេះ! មើលឈុតគម្រូថ្មីរបស់គេសិនទៅ!
យី បូ៉ា! រឿង ១៨ បូកហ្នឹង? ម៉េចឲ្យខ្ញុំមើលរឿងចឹងៗ?
រោគចិត្ត
លក់មុខណាស់ខ្ញុំ !


ទឺត ទឺត
អាឡូ បូរ៉ា! កម្មវិធីនៅផ្ទះល្ងាចនេះកូនមានរៀបចំហើយ ឬនៅ?
បាទម៉ែ! ចាំខ្ញុំទៅដល់ផ្ទះ ចាំរៀបចំ !!


កូនអើយ! ម៉េច ចេញរូបផ្តេសផ្តាស ពេញអេក្រង់ចឹង?
បូរ៉ា បូរ៉ា...បិទៗកុំព្យូទ័រ!
គឺថា....នែក !!!
បូរ៉ា!! ឯងធ្លាប់ធ្វើអីលើ អ៊ីនធឺណិតហើយ ទើបចេញចឹង។
អត់មានទេ ខ្ញុំចង់ទិញកាដូឲ្យប្រពន្ធ ហើយក៏ស្វែងរកតាម អ៊ីនធឺណិតទៅ



ប្អូន! បើ ប្អូន ឯងចង់ស្វែងរកទិញទំនិញតាមអ៊ីនធឺណិត
ចុះវាខុសគ្នាអីជាមួយកម្មវិធីធម្មតា?
គួរប្រើ TOR BROWSER ឬ ONION BROWSER។
Onion browser
វាមិនបង្ហាញផ្ទាំងពាណិជ្ជកម្មដូច ប្អូន ឯងចង់ទេ ហើយវាមិនតាមដានយើងពីការស្វែងរករបស់យើងទៀតផង។ ចឹងទៅ ប្អូន មិនបាច់បារម្ភទៀតទេ។
អូ ចឹងទេហ៎! តោះៗច្រៀងតដាក់ចម្រៀងឲ្យ ប្អូន មួយបទល្បងប្រពន្ធទៅចឹង។
បទណាក៏បានដែរ
បទសប្បាយៗទៅចឹង! សុំទឹកមួយផ្តិលៗ
សុំទឹកមួយផ្តិល មកណាំប្រុសបង !! បានទេ? បានទេ? ល្បងល្អង

# តើអ្វីជាកម្មវិធីរុករក Tor ឬ Onion?

**Tor ឬ Onion** ជាកម្មវិធីរុករកដែលប្រើប្រាស់បណ្ដាញឯកជនរបស់ **Tor ឬ Onion** ដើម្បីការពារឯកជនភាព និង បិទបាំងអត្តសញ្ញាណរបស់អ្នកនៅលើអ៊ីនធឺណិតមានសុវត្ថិភាពខ្ពស់។

**Tor ឬ Onion** ជាកម្មវិធីដែលបើកកូដចំហ (Open Source) និង មិនរក្សាទុកប្រវត្តិនៃការប្រើប្រាស់អ៊ីនធឺណិតរបស់អ្នកនោះទេ។

**Tor** សម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការ **Windows, MacOS, Linux** និង **Android**។

**Onion** សម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការ **iOS** មានដូចជា **iPhone** និង **iPad**។

# តើកម្មវិធីនេះដំណើរការដូចម្តេច ?

អ្នកប្រើប្រាស់ចូលបើកមើលវេបសាយដែលគេបិទ (រាំងខ្ទប់) តាមរយៈកម្មវិធីរុករក **Tor** ហើយ **Tor** ភ្ជាប់ទៅកាន់បណ្តាញ **Tor** រួចបញ្ជូនចរាចរណ៍អ៊ីនធឺណិតដែលបានធ្វើកូដនីយកម្មឆ្លងកាត់ម៉ាស៊ីនបញ្ជូនបន្តចំនួនបីរបស់បណ្តាញ **Tor** ដើម្បីរក្សាសុវត្ថិភាពទិន្នន័យ។ ម៉ាស៊ីនបញ្ជូនបន្តចុងក្រោយជាម៉ាស៊ីនចូលបើកប្រើវេបសាយដោយអនាមិក ដោយគ្មាននរណាម្នាក់ដឹងពីអត្តសញ្ញាណរបស់អ្នកឡើយ។



# ហេតុអ្វីអ្នកគួរប្រើ Tor ឬ Onion ?



កូដនីយកម្មចរាចរណ៍អ៊ីនធឺណិត



ការពារពីការតាមដាននៅលើអ៊ីនធឺណិត



ជៀសផុតពីការឃ្លាំមើលនៅលើអ៊ីនធឺណិត



ជៀសផុតពីការរឹតត្បិត



ការពារឯកជនភាពរបស់អ្នកនៅ
លើអ៊ីនធឺណិត និង ឥតគិតថ្លៃ

ទាញយកកម្មវិធី
**Onion** នៅទីនេះ

ទាញយកកម្មវិធី
**Tor** នៅទីនេះ